# ប្រាសាទអង្គរវត្តជាកេរ្តិ៍ដំណែលវប្បធម៌នៃអរិយធម៌ខ្មែរ

២០០៦

ប្រទេសកម្ពុជាស្ថិតនៅចំណុចកណ្តាលនៃភូមិភាគអាស៊ីអាគ្នេយ៍ហើយត្រូវបែងចែកជាពីរដោយទន្លេមេគង្គ។ តាមប្រវត្តិសាស្ត្រប្រទេសកម្ពុជា ទឹកទន្លេមេគង្គនិងបឹងទន្លេសាបដែលជាបឹងទឹកសាបដ៏ធំជាងគេនៅលើពិភពលោក ជាដំណាងនៃសរសៃឈាមទ្រទ្រង់ប្រទេសជាតិ។ នៅក្នុងសម័យអង្គរ ប្រព័ន្ធធារាសាស្ត្ររបស់ខ្មែរមានការរីកចំរើនយ៉ាងអស្ចារ្យ។ នាសម័យនោះ ទឹកមិនត្រឹមតែមានតួនាទីយ៉ាងសំខាន់ក្នុងវិស័យកសិកម្មប៉ុណ្ណោះទេ ព្រមទាំងជានិមិត្តរូបយ៉ាងសំខាន់ក្នុងវិស័យស្ថាបត្យកម្មទៀតផង។

អង្គរជាចំនុចកំពូលនៃអរិយធម៌ខ្មែរ ចាប់តាំងពីដើមសតវត្សទី១ មុនគ្រិស្តសករាជ។ ស្នាដៃសិល្បៈបែបព្រះពុទ្ធសាសនា និងព្រហ្មញ្ញសាសនា ដំបូងគឺចាប់ផ្តើមពីសតវត្សទី៦។ ការកកើតនៃអាណាចក្រខ្មែរនាសម័យអង្គរនៅភាគខាងជើងនៃដងទន្លេសាបចាប់ផ្តើមពីសតវត្សទី៩។ ក្នុងសម័យដ៏រុងរឿង អាណាចក្រខ្មែរបានគ្រប់គ្រងតំបន់នៃប្រទេសកម្ពុជាបច្ចុប្បន្ន វៀតណាមខាងជើង ប្រទេសឡាវ និងចំនុចកណ្តាលនៃវាលទំនាបចៅប្រយ៉ាក្នុងប្រទេសថៃសព្វថ្ងៃនេះ។ ប្រជាជនខ្មែរជាប្រជាជនមួយដែលមានចំនួនច្រើន និងមានអំនាចក្នុងចំនោមប្រជាជាតិក្នុងតំបន់អាស៊ី។នៅក្នុងសតវត្សទី១៣ អាណាចក្រខ្មែរមានការរីកចំរើនយ៉ាងខ្លាំង ដោយមាននូវប្រាសាទជាច្រើន ដែលនៅក្នុងនោះមានប្រាសាទអង្គរវត្ត ដែលគេចាត់ទុកថាជាប្រាសាទដ៏ធំជាងគេនៅលើពិភពលោក។

ការតាំងពិពណ៌នេះនឹងបង្ហាញនូវវប្បធម៌ខ្មែរដែលមានតែមួយគត់ដែលចាប់ផ្តើមក្នុងសតវត្សទី៦ រួមមានការបង្ហាញថ្មនិងរូបចំលាក់ឈើជាច្រើននាសម័យមុនអង្គរគឺក្នុងអាណាចក្រហ្វូណន និងអាណាចក្រចេនឡា ព្រមទាំងការឡើងដល់កំពូលនៃសិល្បៈនិងស្ថាបត្យកម្មនៃសម័យអង្គរពីសតវត្សទី៩ដល់សតវត្សទី១៣រួមទាំងមានការគ្រប់គ្រងផ្លូវទឹក ការធ្វើស្រែកសិកម្ម និងជំនួញក៏នឹងត្រូវ លើកយកមកបង្ហាញ ព្រោះទាំងអស់នេះជាគោលសំខាន់នៃភោគទ្រព្យដ៏អស្ចារ្យសំរាប់ប្រទេស។ សមិទ្ធិផលសិល្បៈនៃសម័យអង្គរដែលមានរូបចំលាក់អំពីថ្ម បដិមាករអំពីទង់ដែង សិលាចារិក និងស្នាដៃស្ថាបត្យកម្មផ្សេងៗ ព្រមទាំងរូបថតនឹងត្រូវបានដាក់បង្ហាញនៅក្នុងការតាំងពិពណ៌នេះផងដែរ។